ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តសៀមរាប

-សាលក្រមរដ្ឋប្បវេណីលេខៈ ០៨ "ឆ"/ ៤៩
ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣
-សំណុំរឿងរដ្ឋប្បវេណីលេខៈ ៥១១
ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២

# សាលក្រម
# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តសៀមរាប

-បានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ ព្រឹក នៅសវនាការ នៃសាលាដំបូង ខេត្តសៀមរាប។

-បានប្រកាសសាលក្រម នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ព្រឹក នៅសវនាការ នៃសាលាដំបូង ខេត្តសៀមរាប។

## ចៅក្រមជំនុំជម្រះ

លោកស្រី [redacted] ចៅក្រមសាលាដំបូង ខេត្តសៀមរាប

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូង ខេត្តសៀមរាប

លើសំណុំរឿងរដ្ឋប្បវេណីលេខ ៥១១ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ដែលមានៈ

-**ដើមចោទ**ឈ្មោះ [redacted] ឆេងគាង ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋាន [redacted]។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

-**សហចុងចម្លើយ**ឈ្មោះ [redacted] ម៉ានឿត ភេទស្រី កើតឆ្នាំ១៩៨០ ជនជាតិខ្មែរ សញ្ជាតិខ្មែរ និងប្ដី ឈ្មោះ [redacted] ច័ន្ទសេង កើតឆ្នាំ១៩៨៣ អាសយដ្ឋាន [redacted]។



Scanned with CamScanner

## អង្គហេតុ និងចំណុចវិវាទ

### I- ការទាមទាររបស់ដើមចោទ:

ដើមចោទបានប្តឹងសុំទាមទារឱ្យតុលាការចេញសាលក្រម ដូចខាងក្រោម:

១.ឱ្យសហចុងចម្លើយសងប្រាក់ចំនួន ២៦.០៨០.៨០០ (ម្ភៃប្រាំមួយលាន សូន្យរយប៉ែតសិបពាន់ ប្រាំបីរយ) រៀល មកឱ្យដើមចោទ។

២.ឱ្យសហចុងចម្លើយសងការខូចខាត ការខាតបង់ពេលវេលា ជម្ងឺចិត្ត និងសេវាមេធាវីចំនួន ៤០.០០ ០.០០០ (សែសិបលាន) រៀល។

៣.ប្រកាសអនុវត្តបណ្តោះអាសន្ន ត្រង់ចំណុចទី១នៃការទាមទារ។

៤.ឱ្យសហចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

### II-ការសង្ខេបអំពីរឿងក្តី

សហចុងចម្លើយឈ្មោះ [redacted] ម៉ានឿត និងប្តីឈ្មោះ [redacted] ច័ន្ទសេង បានទិញសំឡីគរ ពីដើមចោទ ឈ្មោះ [redacted] ឆេងគាង ចំនួន បីលើក ហើយបច្ចុប្បន្ននៅសល់ប្រាក់ ចំនួន ២៦.០៨០.៨០០ (ម្ភៃប្រាំមួយ លាន សូន្យរយប៉ែតសិបពាន់ ប្រាំបីរយ) រៀល ដែលមិនទាន់បានទូទាត់ឱ្យទៅដើមចោទ ហើយសហចុង ចម្លើយបានទទួលដំណឹងពីដីកាកោះហៅ និងការជូនដំណឹងពីនីតិវិធីផ្សេងរបស់តុលាការ ប៉ុន្តែសហចុង ចម្លើយមិនបានចូលខ្លួនមកឆ្លើយបំភ្លឺនោះទេ មានន័យថា សហចុងចម្លើយទទួលស្គាល់នូវការទាមទាររបស់ ដើមចោទ។

### III-សេចក្តីថ្លែងការណ៍របស់គូភាគី

ឈ្មោះ [redacted] ឆេងគាង ជាដើមចោទបានថ្លែងការណ៍ថា សហចុងចម្លើយបានទិញសំឡីគរពីខ្លួន តាមទូរស័ព្ទ ចំនួន បីលើក គឺលើកទី១ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ ទិញចំនួន ១០.៣០៦ គីឡូ តម្លៃ ២.៨០០រៀល ក្នុងមួយគីឡូ គិតជាប្រាក់សរុបចំនួន ២៨.៨៥៦.៨០០ រៀល។ លើកទី២ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៩ ទិញសំឡីបន្ថែម ចំនួន ៩.៨១៤គីឡូ ក្នុងតម្លៃ ២.៨០០រៀល ក្នុងមួយគីឡូ គិតជាប្រាក់ សរុប ចំនួន ២៧.៤៧៩.០០រៀល និងលើកទី៣ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៩ ទិញសំឡីបន្ថែម ចំនួន ៩.៨៦៨គីឡូ តម្លៃ ២.២០០រៀល ក្នុងមួយគីឡូ សរុបទឹកប្រាក់ ចំនួន ២៧.៧០៩.០០០ រៀល។ ការទូទាត់ប្រាក់របស់សហចុងចម្លើយ គឺគាត់ទូរទាត់ឱ្យខ្លួន បន្តបន្ទាប់រហូត ជាហូរហែ តាមវិង ហៀតដល់ទូទាត់ អស់ការទិញលើកទី១ និងទី២ ហើយសហចុងចម្លើយនៅជំពាក់ប្រាក់ខ្លួន ចំនួន ២៦.០៨០.៨០០ (ម្ភៃប្រាំ មួយលាន សូន្យរយប៉ែតសិបពាន់ ប្រាំបីរយ) រៀល សម្រាប់ការទិញសំឡីគរ លើកទី៣ ដែលគាត់មិនទាន់



Scanned with CamScanner

បានទូទាត់ឱ្យខ្លួន ដោយសហចុងចម្លើយ ខកខានទូទាត់ប្រាក់ឱ្យខ្លួនតាំងពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ និងទាក់ទងគាត់មិនបាន ទើបខ្លួនដាក់ពាក្យបណ្ដឹងតែម្ដង។ ចំពោះការទាមទារចំណុចផ្សេងទៀត ខ្លួនរក្សាដដែល។ ដោយសារចុងចម្លើយគាត់មានចេតនាគេចវេសមិនចូលមកឆ្លើយបំភ្លឺ និងមិនចង់សងប្រាក់ដែលជំពាក់មកឱ្យខ្លួន ដូច្នេះ ស្នើសុំតុលាការសម្រេចចេញសាលក្រម តាមការទាមទារ ដោយក្ដីអនុគ្រោះ។

ឈ្មោះ [redacted] ម៉ានឿត និងឈ្មោះ [redacted] ច័ន្ទសេង ជាសហចុងចម្លើយបានទទួលដំណឹងពីដីកាកោះរបស់តុលាការ ប៉ុន្តែអវត្តមាន។

IV-**អង្គហេតុដែលគ្មានវិវាទ** ៖ គ្មាន។

V-**អង្គហេតុដែលមានវិវាទ** ៖ តើការទាមទារប្រាក់របស់ដើមចោទ ត្រឹមត្រូវ ឬទេ។

**ការពិនិត្យភស្តុតាង**

I-**ភស្តុតាងជាឯកសាររបស់ដើមចោទ**

ពាក្យបណ្ដឹង ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២២ និងឯកសារភ្ជាប់។

II-**ភស្តុតាងជាឯកសារ និងសាក្សី របស់សហចុងចម្លើយ គ្មាន។**

VI-**សំអាងហេតុ**

តាមលទ្ធផលនៃការសាកសួរ និងការពិនិត្យភស្តុតាងនានា ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់តុលាការ **យល់ឃើញថា៖**

**១**-តាមពាក្យបណ្ដឹង ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២២ របស់លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ស្របតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បី តុលាការយកមកពិនិត្យ និងសម្រេចតាមច្បាប់បាន។

**២**-តាមសេចក្ដីថ្លែងការណ៍របស់ដើមចោទថា សហចុងចម្លើយឈ្មោះ [redacted] ម៉ានឿត និងប្ដីឈ្មោះ [redacted] ច័ន្ទសេង បានទិញសំឡីគរពីខ្លួន ចំនួន បីលើក និងបច្ចុប្បន្ននៅសល់ប្រាក់ ចំនួន ២៦.០៨០.៨០០ (ម្ភៃប្រាំមួយលាន សូន្យរយប៉ែតសិបពាន់ ប្រាំបីរយ) រៀល ដែលមិនទាន់បានទូទាត់ឱ្យទៅដើមចោទ ដូច្នេះ តុលាការនឹងពិនិត្យសម្រេចតាមភស្តុតាងជាក់ស្ដែង។

**៣**-តាមកិច្ចសន្យាទិញ លក់ សំឡីគរ និងលិខិតសងប្រាក់ទិញ លក់ សំឡីគរ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ តុលាការយល់ឃើញថា សហចុងចម្លើយឈ្មោះ [redacted] ម៉ានឿត និងប្ដីឈ្មោះ [redacted] ច័ន្ទសេង ពិតជាបានបញ្ជាទិញ សំឡីគរ ពីដើមចោទ ចំនួន បី លើក នៅសល់ប្រាក់ចំនួន ២៦.០៨០.៨០០ (ម្ភៃប្រាំមួយលាន សូន្យរយប៉ែតសិបពាន់ ប្រាំបីរយ) រៀល ដែលមិនទាន់ទូទាត់ឱ្យដើមចោទ។ សហចុងចម្លើយ បានទទួលដំណឹងពីដីកាកោះហៅ និងលទ្ធផលនៃគ្រប់នីតិវិធីរបស់



Scanned with CamScanner

តុលាការ ប៉ុន្តែសហចុងចម្លើយ មិនបានចូលខ្លួនមកឆ្លើយបំភ្លឺ ឬការពារខ្លួនពីការទាមទាររបស់ដើមចោទនោះទេ មានន័យថា សហចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងទៅនឹងអង្គហេតុនូវគ្រប់ចំណុចនៃការទាមទាររបស់ដើមចោទ ដូច្នេះ តុលាការនឹងទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយសាលក្រម តាមបញ្ញត្តិមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**៤**-ដើមចោទបានទាមទារសំណងថ្លៃខូចខាត ការខាតបង់ពេលវេលា ជម្ងឺចិត្ត និងសេវាមេធាវី ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ដោយហេតុថា សហចុងចម្លើយបានបង្កើតឱ្យមានកំហុស ដែលបានខកខានមិនបានបង់ប្រាក់ តាមកាលកំណត់មកឱ្យដើមចោទ និងធ្វើឱ្យដើមចោទ ខាតបង់ពេលវេលា បាត់បង់ផលប្រយោជន៍ សោហ៊ុយក្នុងការចំណាយ ដំណើរការរឿងក្តីនេះឡើង។ តុលាការយល់ឃើញថា សហចុងចម្លើយ គឺជាអ្នកមានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ច ដូច្នេះ តុលាការសម្រេច ឱ្យសហចុងចម្លើយសងខូចខាត ថ្លៃជម្ងឺចិត្ត ខាតបង់ពេលវេលា និងសេវាមេធាវី ទៅឱ្យដើមចោទ តាមភាពសមហេតុផល យោងតាមបញ្ញត្តិមាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណី។

**៥**-ដើមចោទបានទាមទារសុំអនុវត្តសាលក្រមបណ្តោះអាសន្ន ត្រង់ចំណុចទី**១** ដោយសារសហចុងចម្លើយពិតជាមិនទាន់សងប្រាក់ឱ្យទៅដើមចោទ ប្រាកដមែន ដែលការយឺតយ៉ាវក្នុងការសងប្រាក់នេះ ធ្វើឱ្យដើមចោទ រងការខូចខាតផ្នែកសេដ្ឋកិច្ច ដូច្នេះ ការរង់ចាំដល់សេចក្តីសម្រេចចូលជាស្ថាពរនោះ អាចមានការយឺតយ៉ាវ ជាហេតុធ្វើឱ្យរាំងស្ទះនូវការអនុវត្តសិទ្ធិរបស់ដើមចោទដែលជាម្ចាស់ទ្រព្យ។ ការពារដើមចោទ កុំឱ្យមានការខូចប្រយោជន៍ស្របច្បាប់របស់ខ្លួន និងដើម្បីរក្សាតុល្យភាពជាមួយនឹងបណ្តឹងឧបាស្រ័យ ទៅតុលាការជាន់ខ្ពស់ តុលាការ យល់ឃើញថា សំណុំរឿងនេះមានភាពចាំបាច់ដែលតុលាការ គប្បី សម្រេចឱ្យអនុវត្តជាបណ្តោះអាសន្ន តាមការប្តឹងសុំត្រង់ចំណុចទី១ នៃពាក្យបណ្តឹង ដែលជាការទាមទារចាំបាច់ យោងតាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**៦**-ដើមចោទទាមទារប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់សហចុងចម្លើយ ដូច្នេះ តុលាការនឹងសម្រេចតាម បញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**សេចក្តីសម្រេចបញ្ចប់**

**១.បង្គាប់**ឱ្យសហចុងចម្លើយឈ្មោះ ព្រាប ម៉ានឿត និងប្តីឈ្មោះ [redacted] ច័ន្ទសេង រួមគ្នាសងប្រាក់ចំនួន **២៦.០៨០.៨០០** (**ម្ភៃប្រាំមួយលាន ប៉ែតសិបពាន់ ប្រាំបីរយ**) **រៀល** មកឱ្យដើមចោទឈ្មោះ [redacted] ឆេងគាង។

**២.បង្គាប់**ឱ្យសហចុងចម្លើយឈ្មោះ [redacted] ម៉ានឿត និងប្តីឈ្មោះ [redacted] ច័ន្ទសេង រួមគ្នាសងសំណងការខូចខាត និងជម្ងឺចិត្ត ចំនួន **២.០០០.០០០** (**ពីរលាន**) **រៀល** ឱ្យទៅដើមចោទឈ្មោះ [redacted] ឆេងគាង។

**៣.**ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់សហចុងចម្លើយឈ្មោះ [redacted] ម៉ានឿត និងប្តីឈ្មោះ [redacted] ច័ន្ទសេង។

**៤.**សាលក្រមនេះ មានអនុភាពអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី**១** នៃសេចក្តីសម្រេច។

-បានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសសាលក្រម ចំពោះមុខដើមចោទ និងកំបាំងមុខសហចុងចម្លើយ។

-ទុកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា** [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១០រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅសៀមរាប, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]